**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~~

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# សេចក្តីជូនដំណឹងសម្រាប់ប្រព័ន្ធព័ត៌មានស្តីពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

ថ្ងៃពុធ ១៥កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១១:០០ នាទីព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង លោកស្រី **Sunniya Durrani-Jamal** នាយិកាស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសម្រាប់គម្រោង និងកម្មវិធីចំនួន ០៤ ដែលមានទឹកប្រាក់សរុបជិត ២៥០ លានដុល្លារអាមេរិក ដូចខាងក្រោម÷

***១) កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិដំណាក់កាលទី២*** គ្រោងចំណាយថវិកាសរុបប្រមាណ ៥៣,៥០ លានដុល្លារអាមេរិក សម្រាប់អនុវត្តយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ និងការព្យាករណ៍តម្រូវការអភិវឌ្ឍន៍វិស័យអប់រំឆ្នាំ ២០២០ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ដែលផ្តោតលើ÷

**(ក) កម្មវិធីគោលនយោបាយវិស័យអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិដំណាក់កាលទី២** សម្រាប់ការបង្កើនគុណភាពគ្រូបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ,ការបង្កើនគុណភាព និងការឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការរៀបចំផែនការគ្រប់គ្រងសាលារៀន និងការផ្តល់ការអប់រំ ។

**(ខ) កម្មវិធីវិនិយោគ**ដើម្បីបង្កើនប្រសិទ្ធិភាពប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិតាមរយៈ÷

- ការពង្រឹង និងកែប្រែវិទ្យាស្ថានជាតិអប់រំ ឱ្យក្លាយជាកន្លែងបណ្តុះបណ្តាល និងវិក្រឹតការគ្រូទុតិយភូមិក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។
- ការបង្កើនគុណភាពអប់រំនៅសាលាមធ្យមសិក្សាទុតិយភូមិ។
- ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌកម្មវិធីសិក្សាថ្មី, ការគ្រប់គ្រង និងការដឹកនាំដល់ថ្នាក់គ្រប់គ្រងសាលា, មន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាលនៅតាមវិទ្យាល័យធនធាន។

***២) គម្រោងកែលម្អការគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាបដំណាក់កាលទី២*** គ្រោងចំណាយថវិកាសរុបប្រមាណ ៩៧,៧០ លានដុល្លារអាមេរិក សម្រាប់ការអភិវឌ្ឍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្រុងអាទិភាពចំនួន ០៣ (ក្រុងស្ទឹងសែន, ក្រុងសិរីសោភ័ណ្ឌ និងក្រុងបាត់ដំបង) តាមរយៈការសាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន ៣,ប្រព័ន្ធបណ្តាញលូ និងសាងសង់ទីលានចាក់សំរាម ។ គម្រោងនេះ ក៏នឹងជួយពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធដើម្បីផ្តល់សេវា និង កែលំអគោលនយោបាយគ្រប់គ្រងកាកសំណល់រឹង, ទឹកកខ្វក់, បណ្តាញលូរំដោះទឹកភ្លៀងក្រុង និងបរិស្ថានប្រកបដោយនិរន្តរភាពផងដែរ ។
~~~~~~~~

***៣) គម្រោងអភិវឌ្ឍន៍ទីក្រុងរបៀងនៃមហាអនុតំបន់មេគង្គជំហានទី៤*** គ្រោងចំណាយថវិកាវិនិយោគសរុបប្រមាណ ៨៨,៥០ លានដុល្លារអាមេរិក សម្រាប់ការពង្រីកសេវាសាធារណៈនៅទីប្រជុំជនដែលនឹងជួយលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់តាមរយៈការអភិវឌ្ឍក្រុងរបៀងអាទិភាពចំនួន០៣ (ក្រុងកំពង់ចាម, ក្រចេះ និងស្ទឹងត្រែង ដែលជាក្រុងរបៀងនៃមហាអនុតំបន់មេគង្គ) ដោយរួមមាន÷ការសាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់, ការតភ្ជាប់ប្រព័ន្ធលូរំដោះទឹកដល់ប្រជាជន, ការសាងសង់ទីលានចាក់សំរាម និងការសាងសង់ស្ថានីយ៍បូមទឹកកខ្វក់ ។

*គម្រោងកែលម្អការគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាបជំហានទី២ និងគម្រោងអភិវឌ្ឍន៍ទីក្រុងរបៀងនៃមហាអនុតំបន់មេគង្គជំហានទី៤ នឹងចូលរួមអនុវត្ត÷ (១) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ - ២០១៨ ដែលផ្តោតលើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង (២) គោលនយោបាយជាតិស្តីពីវិស័យទឹកស្អាត និងអនាម័យរបស់រាជរដ្ឋាភិបាល ។*

***៤) គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាប័ន្នក្នុងមហានុតំបន់មេគង្គជំហានទី២*** គ្រោងចំណាយថវិកាវិនិយោគសរុបប្រមាណ ៣០,៨៩ លានដុល្លារអាមេរិក ក្នុងគោលបំណងបង្កើនការទាក់ទាញទេសចរណ៍ក្នុងខេត្តគោលដៅចំនួន ០២ (ខេត្តកែប និងខេត្តព្រះសីហនុ) ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងកសាងកំពង់ផែទេសចរណ៍ខ្នាតតូចចំនួន ២, ការធ្វើឱ្យប្រសើរឡើងនូវអនាម័យទីក្រុង, និងការកសាងសមត្ថភាពក្នុងការគ្រប់គ្រងកំណើនទេសចរណ៍ប្រកបដោយចីរភាព។ ជាមួយគ្នានេះ គម្រោងក៏នឹងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រទេសចរណ៍ ASEAN ឆ្នាំ២០១៦ - ២០២៥ និងជួយបង្កើនសកម្មភាពពាណិជ្ជកម្មក្នុងតំបន់តាមរយៈការលើកកម្ពស់វិស័យទេសចរណ៍ឆ្លងដែន, និងការធ្វើសមាហរណកម្មរវាង GMS និង ASEAN ឱ្យកាន់តែមានភាពស៊ីជម្រៅថែមទៀតផងដែរ។

បន្ថែមទៅនឹងគោលដៅខាងលើ គម្រោង និងកម្មវិធី ទាំង ០៤ នេះ សុទ្ធតែមានគោលដៅរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ADB និងមូលនិធិភាពជាដៃគូរបស់សាធារណរដ្ឋកូរ៉េសម្រាប់ពុទ្ធិពតិមានវិទ្យានៅអាស៊ី (Republic of Korea e-Asia Knowledge Partnership Fund) ដែលបានផ្តល់ការជឿទុកចិត្ត និងជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការអនុម័តផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងខាងលើ និងបានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍនៅកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន តាមរយៈការបន្តធានាសម្រេចឱ្យបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកឡើងវិញអំពីកិច្ចសហប្រតិបត្តិការ ADB ដែលបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបប្រមាណ ៣,១៩ ប៊ីលានដុល្លារអាមេរិក ដោយគិតបញ្ចូលទាំងកិច្ចព្រមព្រៀងរបស់គម្រោង/កម្មវិធីទាំង ០៤ ដែលបានចុះហត្ថលេខក្នុងថ្ងៃនេះ ដែលក្នុងនោះ ឥណទានសម្បទានមានទឹកប្រាក់សរុបចំនួន ២,៧០ ប៊ីលានដុល្លារអាមេរិក និងហិរញ្ញប្បទានឥតសំណងមានទឹកប្រាក់សរុបចំនួនប្រមាណ ៤៩០ លានដុល្លារអាមេរិក។ ទាំងនេះ បង្ហាញពីការប្តេជ្ញាបន្តពង្រឹងភាពជាដៃគូដ៏រឹងមាំរបស់ ADB ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

*ថ្ងៃពុធ ១៥កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*

*រាជធានីភ្នំពេញថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨*